

# ជ្រូក ហាមចូល

Let's Read
The Asia Foundation



ជាយូរលង់មកហើយ ក្រុមសត្វមានស្នែងបានសម្រេចចិត្តធ្វើពិធីជប់លៀងនៅលើកំពូលភ្នំ។
ពួកគេហៅតែសត្វដែលមានស្នែងមកចូលរួមទេ។ គ្មានសត្វផ្សេងទៀតទេ។



នៅពេលជ្រូកបានឮពីការជប់លៀងនោះ វាបានគិតថា «ខ្ញុំគ្មានស្នែងទេ។ តើខ្ញុំគួរធ្វើម៉េចទៅ?»



នៅថ្ងៃបន្ទាប់ វាបានគិតឃើញគំនិតមួយ។ វាបានយកស្នែងមក
បិទជាប់នឹងក្បាលវាដោយក្រមួន!



ពិតជាបានផលមែន ហើយជ្រូកយល់ថា ខ្លួនឯងឆ្លាតណាស់ នៅពេលដែលគេអនុញ្ញាតឱ្យចូលក្នុងពិធីជប់លៀងនោះ។ បញ្ហាគឺ ពិធីជប់លៀងនោះធ្វើឡើងនៅកន្លែងដែលជិតព្រះអាទិត្យ។



នៅពេលដែលថ្ងៃក្ដៅខ្លាំង ក្រមួនបានរលាយ។ ស្នែងរបស់ជ្រូកក៏បានធ្លាក់ចុះមក។ សត្វដែលមានស្នែងទាំងអស់តក់ស្លុត។ ពួកគេបានសួរ ៖ «តើសត្វគ្មានស្នែងនោះជាអ្នកណា? ហេតុអ្វីបានជាវាមកទីនេះ?»



ស្ដេចសត្វបានបញ្ជា ៖ «ចាប់លើកជ្រូកនោះឡើង ហើយបោះវាទៅក្រោមទៅ!»។ ពួកគេបានចាប់ជ្រូក ហើយបោះវាចុះទៅក្រោម។





គួរឱ្យអាណិតជ្រូកណាស់! នៅពេលវាធ្លាក់ ច្រមុះរបស់វាបាន
បុកនឹងដី ដែលធ្វើឱ្យច្រមុះសំប៉ែតចូលគ្នា។



ចាប់តាំងពីពេលនោះមក សត្វជ្រូកក៏មានច្រមុះសំប៉ែតមកដល់សព្វថ្ងៃនេះ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*No Pigs Allowed*, Published by African StoryBook, © African StoryBook. Released under CC BY 3.0.

This work is a modified version of the original story. © The Asia Foundation, 2017. Some rights reserved. Released under CC BY 3.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/3.0/

Contributing translators: Sodany Ouch